# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៦ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៧ ស្តីពី ការបង្កើតគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយមនិងជាប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរ ក្នុងព្រះរាជាណាចក្រកម្ពុជា

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានធ្វើការកែសម្រួលអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ ២០០៨ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់ផ្ទៃបឹងជើងឯក និងប្រឡាយ ស្ថិតនៅក្នុងខណ្ឌមានជ័យ និងខណ្ឌដង្កោ

រាជធានីភ្នំពេញ និងស្រុកតាខ្មៅ ខេត្តកណ្តាល ជាសម្បត្តិសាធារណៈរបស់រដ្ឋ ដោយធ្វើការកែសម្រួលពីនិយាមការលេខ A58, A59, A60, A61 នៃអនុក្រឹត្យខាងលើ ទៅជានិយាមការថ្មីតែមួយចំណុចគឺនិយាមការលេខ A78 មានអាប់ស៊ីស 491979 និងអ័រដោនេ 1273746 ។

**មាត្រា ២ :** ផែនទីបង្ហាញទីតាំងភូមិសាស្ត្រដែលបញ្ជាក់ពីផ្ទៃបឹងត្រូវកែសម្រួល ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានគណៈកម្មាធិការកំណត់ផ្ទៃទីតាំងបឹងបួរក្នុងព្រះរាជាណាចក្រកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ


A57
A78
A62
A64
A18
A19
A17
A21
A22
A23
A16
A3
A4
0
125
250
500
750
1,000
Meters